# គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា
## សេចក្តីសង្ខេបស្តីពីក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន

### អំពីគម្រោង

គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា នឹងធ្វើការកែលម្អផ្លូវពីកម្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ សំដៅធ្វើឲ្យផ្លូវមានភាពធន់នឹងការបម្រែបម្រួលអាកាសធាតុ ស្ថិតនៅក្នុងខេត្តគោលដៅ។ រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំឲ្យធនាគារពិភពលោកផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគលើការងារកែលម្អផ្លូវនៅព្រះរាជាណាចក្រកម្ពុជា។ ខេត្តគោលដៅ ត្រូវអនុវត្តគម្រោងរួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ដែលមានប្រជាជនសរុបប្រមាណជា ២,៣ លាននាក់ ដោយទស្សនទាននៃការរៀបចំគម្រោងនេះឡើង ដើម្បីកែលម្អស្ថានភាពផ្លូវ និងអភិវឌ្ឍផ្លូវថ្នល់ រួមមានផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ឲ្យមានលក្ខណៈល្អប្រសើរ តភ្ជាប់គ្នាជាលក្ខណៈបណ្តាញ សំដៅជួយសម្រួលដល់ការធ្វើដំណើរពីតំបន់ជនបទ ឆ្ពោះទៅកាន់ទីសាលារៀន មណ្ឌលសុខភាព ផ្សារ ទីប្រជុំជន និងបណ្តាញផ្លូវសំខាន់ៗផ្សេងទៀត។ ការកំណត់ជ្រើសរើសខេត្តគោលដៅ ផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចជា៖ ដង់ស៊ីតេប្រជាជនរស់នៅតាមជនបទ សក្តានុពលកសិកម្ម តំបន់ដែលងាយរងគ្រោះដោយសារទឹកជំនន់ ស្ថានភាពផ្លូវ និងការតភ្ជាប់បណ្តាញជាមួយផ្លូវខេត្ត ដើម្បីគ្របដណ្តប់លើតំបន់ភូមិសាស្ត្រកាន់តែធំ។

សមាសភាគទី២ នៃគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា ត្រូវអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ គាំទ្រកែលម្អផ្លូវជនបទ ដែលមានអាទិភាពនៅក្នុងខេត្តគោលដៅ ប្រវែងប្រមាណជា ២៥០ គីឡូម៉ែត្រ ត្រូវអនុវត្តតាមអភិក្រមនៃនីតិវិធីលទ្ធកម្ម «កិច្ចសន្យាផ្អែកលើសមិទ្ធិកម្ម ឬហៅកាត់ថា OPBRC» ដោយត្រូវកែលម្អ និងថែទាំផ្លូវជនបទពីកម្រាលក្រួសក្រហម និងកម្រាលដីស ឲ្យទៅជាផ្លូវកម្រាលកៅស៊ូពីរជាន់ប្រភេទ DBST ពង្រីកតួផ្លូវតាមទីតាំងសមស្រប និងក្រាលបេតុង កែលម្អប្រព័ន្ធបង្ហូរទឹក កសាងសំណង់សិល្បការប្បន្ថែម សម្រាប់តំបន់ដែលងាយលិចទឹក ដើម្បីការពារ និងកាត់បន្ថយបញ្ហាទឹកជំនន់ ព្រមទាំងរៀបចំវិធាននានាក្នុងការទប់ស្កាត់បញ្ហាសុវត្ថិភាពចរាចរនៅលើដងផ្លូវដែលបានកែលម្អ។

### គោលបំណង

ឯកសារក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន មានគោលការណ៍ ក្រឹត្យក្រម ការណែនាំ និងនីតិវិធីច្បាស់លាស់សម្រាប់វាយតម្លៃពីហានិភ័យ និងផលប៉ះពាល់សង្គម និងបរិស្ថាន ក្នុងការអនុវត្តគម្រោង។ ឯកសារនេះ មានផែនការ និងវិធានការ ក្នុងការកាត់បន្ថយផលប៉ះពាល់នៅកន្លែង ដោយត្រូវរៀបចំការប៉ាន់ស្មានទំហំថវិកាសម្រាប់ដោះស្រាយ ដែលអង្គភាពអនុវត្តគម្រោងត្រូវទទួលខុសត្រូវរៀបចំឯកសារពាក់ព័ន្ធនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង ដោយអនុលោមតាមឯកសារក្របខ័ណ្ឌសង្គម និងបរិស្ថានរបស់ធនាគារពិភពលោក។

ក្របខ័ណ្ឌសង្គម និងបរិស្ថាន បានកំណត់ដូចខាងក្រោម៖
- ពិពណ៌នាសង្ខេបអំពីគម្រោង
- ក្របខ័ណ្ឌច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ណែនាំការអនុវត្តគម្រោងឲ្យមានសង្គតិភាពជាមួយក្របខ័ណ្ឌសង្គម និងបរិស្ថានរបស់ធនាគារពិភពលោក ដោយត្រូវវិភាគស្វែងរកចំណុចខ្វះចន្លោះ
- វិភាគអំពីសក្តានុពល ហានិភ័យ/ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន និងវិធានការកាត់បន្ថយ
- រៀបចំនីតិវិធីក្នុងការកំណត់ និងរៀបចំផែនការគ្រប់គ្រងសង្គម និងបរិស្ថាន(ESMP) និងរៀបចំរចនាសម្ព័ន្ធក្រុមការងារដើម្បីអនុវត្ត
- ការវាយតម្លៃសមត្ថភាពដើម្បីអនុវត្តឯកសារ ESMF និងឧបករណ៍ផ្សេងៗទៀត
- រៀបចំយន្តការដោះស្រាយបណ្តឹងតវ៉ា
- ការតាមដាន និងរាយការណ៍
- រៀបចំផែនការថវិកា

ឯកសារស្តីពីការគ្រប់គ្រងសង្គម និងបរិស្ថាន និងគំរូក្នុងឧបសម្ព័ន្ធ គឺជាមូលដ្ឋានក្នុងការរៀបចំផែនការគ្រប់គ្រងសង្គម និងបរិស្ថាន ការបញ្ជាក់ពីនីតិវិធីក្នុងករណីរកឃើញវត្ថុបុរាណ នីតិវិធីគ្រប់គ្រងការងារ និងក្រមសីលធម៌ និងការត្រួតពិនិត្យ។

ក្រៅពីឯកសារព្រាងស្តីពីក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរៀបចំពិគ្រោះយោបល់ និងផ្សព្វផ្សាយ នូវឯកសារមួយចំនួនទៀតតាមគោលការណ៍នៃឯកសារក្របខ័ណ្ឌសង្គម និងបរិស្ថាន ដូចជា៖ (i) ក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ (ii) ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (iii) ផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ។ ចំពោះរាល់ឯកសារលម្អិតខាងលើអាចស្វែងរកបាននៅក្នុងឯកសារវាយតម្លៃគម្រោងរបស់ធនាគារពិភពលោក។

## ផលប៉ះពាល់ និងវិធានការកាត់បន្ថយ

ដំណាក់កាលនៃការរៀបចំគម្រោង ខណៈខ្សែផ្លូវពុំទាន់ត្រូវបានកំណត់ ទំហំផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន នៅពុំទាន់អាចកំណត់បានច្បាស់លាស់ និងសុក្រឹត្យឡើយ ប៉ុន្តែអាចធ្វើការបាន់ស្មាន និងត្រូវធ្វើបច្ចុប្បន្នភាពក្រោយពេលខ្សែផ្លូវត្រូវបានកំណត់ច្បាស់លាស់។ ផ្អែកតាមឯកសារក្របខ័ណ្ឌសង្គម និងបរិស្ថាន របស់ធនាគារពិភពលោក សម្រាប់គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា ត្រូវអនុវត្តតាមវិធានការកាត់បន្ថយដូចខាងក្រោម៖

ក. គិតទុកជាមុន ជៀសវាងកត្តាហានិភ័យ និងផលប៉ះពាល់កើតឡើង
ខ. ករណីមិនអាចជៀងបាន ត្រូវកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ក្នុងកម្រិតអប្បរមា
គ. ករណីនៅមានផលប៉ះពាល់ទៀត ត្រូវផ្តល់សំណងតាមលក្ខណៈបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ

គម្រោងនេះនឹងនាំមកនូវផលប្រយោជន៍ជាច្រើនដល់សហគមន៍ដូចជា៖ កាត់បន្ថយពេលវេលាធ្វើដំណើរទៅកាន់សាលារៀន មណ្ឌលសុខភាព និងកន្លែងទទួលសេវាសាធារណៈផ្សេងទៀត បង្កើនឱកាសទីផ្សារ និងការងារ ធ្វើអោយការធ្វើដំណើរមានភាពរលូនក្នុងរដូវវស្សា ធ្វើអោយមានភាពប្រសើរឡើងនូវសុវត្ថិភាពចរាចរណ៍ និងបរិយាកាស/បរិស្ថានល្អ ដោយសារផ្លូវមិនហុយ និងមិនបែកផុកទៀត។ ផ្នែកទី៣

តារាងទី៧៖ បញ្ជីហានិភ័យសំខាន់ៗ និងវិធានការកាត់បន្ថយផលប៉ះពាល់រួមមាន៖ គុណភាពទឹក និងបរិយាកាស គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់នៅកន្លែងការងារ អំពើហិង្សាលើស្ត្រី អំពើហិង្សាលើកុមារ ការហូរចូលកម្លាំងពលកម្ម និងការកាន់កាប់ដីធ្លី។ តារាងទី៨៖ វិធានការដាក់លាក់ ដើម្បីកាត់បន្ថយហានិភ័យការប្រើប្រាស់អំពើហិង្សាលើស្ត្រី។

## នីតិវិធីរបស់ក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន

ក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន មានគោលបំណងដើម្បីគ្រប់គ្រងរាល់ផលប៉ះពាល់អវិជ្ជមានទាំងឡាយដែលកើតឡើងដោយសារគម្រោង ត្រូវរៀបចំជាឯកសារគោលការណ៍ណែនាំដើម្បីរាយការណ៍ជូនក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងស្ថាប័ន្ធពាក់ព័ន្ធ និងក្រុមហ៊ុនដែលទទួលកិច្ចសន្យាសាងសង់ សំដៅការរៀបចំផែនការលម្អិតក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង តាមនីតិវិធី និងវិធានដូចមានចែងក្នុងឯកសារសង្គម និងបរិស្ថាន របស់គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា។ ឯកសារនេះ ក៏ជាត្រីយវិស័យក្នុងកិច្ចដំណើការនៃការរៀបចំផែនការគ្រប់គ្រងសង្គម និងបរិស្ថាន នៅពេលខ្សែផ្លូវត្រូវបានកំណត់។

ឯកសារគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសង្គម និងបរិស្ថាន ត្រូវបានរៀបចំឡើងដើម្បីធានាថា៖

- ការស្ថាបនាផ្លូវបានគិតគូអំពីបញ្ហាសង្គម និងបរិស្ថាន ពិសេសសម្រាប់ប្រជាពលរដ្ឋដែលត្រូវទទួលរងផលប៉ះពាល់ពីគម្រោងដោយផ្ទាល់ (វិជ្ជមាន និងអវិជ្ជមាន)
- ការស្ថាបនាផ្លូវបានគិតគូអំពីបញ្ហាយេនឌ័រ និងវប្បធម៌សង្គម និងបញ្ហាសង្គមនានាដែលកើតឡើងនៅតាមខ្សែផ្លូវរបស់គម្រោង
- ក្នុងដំណាក់កាលរៀបចំគម្រោង ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន នឹងអាចកើតមានឡើងនៅអំឡុងពេលអនុវត្តគម្រោង ហើយត្រូវរៀបចំផែនការត្រួតពិនិត្យ និងវិធានការសមស្របដើម្បីអនុវត្តនូវវិធីសាស្ត្រ នីតិវិធី និងឧបករណ៍នានា ដូចមានចែងនៅក្នុងឯកសារផែនការគ្រប់គ្រងសង្គម និងបរិស្ថាន (ESMP) ឯកសារផែនការជនជាតិភាគតិច (IPP) និងឯកសារផែនការដោះស្រាយផលប៉ះពាល់ (RP)
- ឧបករណ៍ដែលត្រូវយកមកប្រើប្រាស់ដើម្បីគ្រប់គ្រងបញ្ហាសង្គម និងបរិស្ថាន រួមមាន៖ ផែនការគ្រប់គ្រងសង្គម និងបរិស្ថាន (ESMP) ផែនការជនជាតិភាគតិច (IPP) និងផែនការដោះស្រាយផលប៉ះពាល់ (RP)
- ចំណុចសំខាន់នៃផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ រួមទាំងយន្តការដោះស្រាយបណ្តឹងតវ៉ា នឹងត្រូវបានយកមកប្រើប្រាស់សម្រាប់រាល់សកម្មភាពរបស់គម្រោង
- ឧបករណ៍សង្គម និងបរិស្ថាន ត្រូវរៀបចំឲ្យមានសង្គតិភាពគ្នារវាងក្របខ័ណ្ឌសង្គម និងបរិស្ថាន របស់ធនាគារពិភពលោក ជាមួយនឹងក្របខ័ណ្ឌច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា
- ការរៀបចំគម្រោងត្រូវពិចារណាអំពីគោលការណ៍ ដូចមានចែងនៅក្នុងឯកសារក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន ព្រមទាំងនីតិវិធីនីមួយៗក្នុងការកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន
- យន្តការក្នុងការកំណត់រកផលប៉ះពាល់ និងហានិភ័យនានា ត្រូវបានរៀបចំក្នុងករណីស្គាល់ខ្សែផ្លូវ
- ត្រូវរៀបចំនីតិវិធី និងការទទួលខុសត្រូវសម្រាប់ការរៀបចំផែនការគ្រប់គ្រងសង្គម និងបរិស្ថាន

ក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន បានរៀបរាប់អំពីនីតិវិធីក្នុងការកំណត់ព្រំដែនរៀបចំផែនការគ្រប់គ្រងសង្គម និងបរិស្ថាន ដោយរួមមានទាំងជំហានលំអិត ព័ត៌មានចាំបាច់ ការទទួលខុសត្រូវ និងតម្រូវការបណ្តុះបណ្តាលដល់បុគ្គលិកគម្រោងដែលទទួលបន្ទុកត្រួតពិនិត្យផែនការគ្រប់គ្រងសង្គម និងបរិស្ថាន។ ត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធអនុវត្តគម្រោងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នពាក់ព័ន្ធអន្តរក្រសួង និងសម្រាប់ទីប្រឹក្សាបច្ចេកទេស និងអ្នកទទួលការសាងសង់ផ្លូវជាដើម។

## ការពិគ្រោះយោបល់ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

សម្រាប់សមាសភាពទី២ នៃគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា នឹងត្រូវរៀបចំសកម្មភាពពិគ្រោះយោបល់ និងទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ដូចមានចែងនៅក្នុងឯកសារផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីធានាថាសហគមន៍ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវបានជ្រាប និងចូលរួមក្នុងដំណើកាលរបស់គម្រោង សំដៅប្រមូលនូវធាតុប្រកបដោយបរិយាប័ន្ន។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ នៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២០ ដើម្បីពិភាក្សាលើសេចក្តីព្រាងឯកសារស្តីពីសង្គម និងបរិស្ថាន ជាមួយក្រសួងស្ថាប័ន្ធពាក់ព័ន្ធមួយចំនួននៅកម្រិតថ្នាក់ជាតិ ហើយឯកសារក្របខ័ណ្ឌសង្គម និងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសធារណៈ នៅក្នុងគេហទំព័រ ឬបណ្ណាល័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងគេហទំព័ររបស់ធនាគារពិភពលោក។

## ការដោះស្រាយបណ្តឹងតវ៉ា

យន្តការបណ្តឹងតវ៉ា ស្វែងរកវិធីសាស្ត្រដោះស្រាយឲ្យទាន់ពេលវេលានូវរាល់ទុក្ខកង្វល់ប្រជាពលរដ្ឋដែលកើតឡើងដោយសារការអនុវត្តគម្រោង តាមរយៈការប្រើប្រាស់វប្បធម៌ដោះស្រាយបញ្ហាប្រកបដោយការយោគយល់គ្នា និងឈានទៅរកការការយល់ព្រមដោយមិនចាំបាច់ផ្តល់សំណងណាមួយ។ យន្តការនេះអាចត្រូវបានអនុវត្តជូនចំពោះបុគ្គលណាមួយ បើសិនគេគិតថាគម្រោងនេះ នឹងធ្វើឲ្យប៉ះពាល់បាត់បង់ប្រយោជន៍ធ្ងន់ធ្ងរដល់គេផ្ទាល់ ដល់សហគមន៍ បរិស្ថាន ឬប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគេ ដោយពួកគេអាចបញ្ជូននូវរាល់មតិយោបល់ និងសំណូមពរមកគម្រោងបាន។ យន្តការដោះស្រាយបណ្តឹងតវ៉ាត្រូវបានពិពណ៌មានលំអិតនៅក្នុងឯកសារគម្រោងស្តីពីផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ

គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា រំពឹងថាអាចមានបណ្តឹងតវ៉ាវ ០៤ ប្រភេទ៖

- បណ្តឹងតវ៉ាពាក់ព័ន្ធបញ្ហាដីធ្លី ដែលត្រូវអនុវត្តតាមផែនការដោះស្រាយផលប៉ះពាល់តាមរយៈអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បណ្តឹងតវ៉ាពាក់ព័ន្ធការអនុវត្តគម្រោងផ្ទាល់ (ផលប៉ះពាល់សង្គម និងបរិស្ថាន សុខភាព សុវត្ថិភាពចរាចរណ៍)
- បណ្តឹតវ៉ាពាក់ព័ន្ធនឹងជនជាតិដើមភាគតិច
- និងវិវាទនានាពាក់ព័ន្ធនឹងកម្មករ (លំអិតក្នុងឧបសម្ព័ន្ធទី៨)

## ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍

ការត្រួតពិនិត្យ គឺជាវិធីសាស្ត្រក្នុងការធានាថា វិធានការកាត់បន្ថយកំពុងត្រូវបានយកមកអនុវត្តប្រកបដោយប្រសិទ្ធិភាព។ ត្រូវរៀបចំធ្វើរបាយការណ៍ត្រួតពិនិត្យប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស ជាចាំបាច់ដើម្បីៈ

- កែលម្អនូវការចំណុចខ្វះខាតក្នុងការអនុវត្តការគ្រប់គ្រងសង្គម និងបរិស្ថាន
- ធានាប្រសិទ្ធភាព និងគុណភាពនៃដំណើរការវាយតម្លៃសង្គម និងបរិស្ថាន
- បង្កើតទម្រង់ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ផ្អែកលើសមិទ្ធកម្ម
- ផ្តល់នូវឱកាសដើម្បីរាយការណ៍ពីលទ្ធផលនៃការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់នៅពេលត្រូវរៀបចំឯកសារ ESMP នាពេលអនាគត និងឯកសារពាក់ព័ន្ធគម្រោងផ្សេងទៀត។

កំឡុងពេលអនុវត្តអនុគម្រោង មន្រ្តីសង្គម និងបរិស្ថាន របស់ក្រសួងអភិវឌ្ឍន៍ជនបទ នឹងរៀបចំប្រតិទិនប្រចាំខែចុះត្រួតពិនិត្យគម្រោងលើផែនការគ្រប់គ្រងសង្គម និងបរិស្ថាន ដើម្បីកំណត់ពីវិធីសាស្ត្រក្នុងការកាត់បន្ថយផលប៉ះពាល់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ក្រុមការងារសង្គម និងបរិស្ថានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ រួមជាមួយទីប្រឹក្សាបច្ចេកទេស និងចុះត្រួតពិនិត្យរួមគ្នាដើម្បីធានាថាវិធានការនៃការកាត់បន្ថយផលប៉ះពាល់ដែលមានចែងនៅក្នុងក្របខ័ណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន ត្រូវបានយកមកប្រើប្រាស់ដោយអ្នកអនុវត្តគម្រោងដូចជា អ្នកទទួលការសាងសង់ និងស្ថាប័នទទួលខុសត្រូវនានា។ មន្រ្តីសង្គម និងបរិស្ថាន និងចុះត្រួតពិនិត្យយន្តការដោះស្រាយបណ្តឹងតវ៉ា លើដំណើការដោះស្រាយផលប៉ះពាល់បញ្ហាដីធ្លីក្នុងគម្រោង ធានាថាបងប្អូនជនជាតិដើមភាគតិចត្រូវបានទទួលអត្ថប្រយោជន៍ប្រកបដោយសមធម៌ និងត្រូវរៀបចំឯកសារចាំបាច់មួយចំនួនដើម្បីអនុវត្តផែនការជាមួយភាគីពាក់ព័ន្ធ និងការផ្សព្វផ្សាយអំពីសកម្មភាពរបស់គម្រោង។

## អំពីថវិកា

ការចំណាយលើការអនុវត្តឯកសារក្របខ័ណ្ឌផែនការគ្រប់គ្រងសង្គម និងបរិស្ថាន នឹងត្រូវផ្តោតលើការរៀបចំឧបករណ៍ជាក់លាក់ស្តីពីសង្គម និងបរិស្ថាន នៅតាមមូលដ្ឋានជាក់ស្តែង ដូចជាការចំណាយលើបុគ្គលិក ការធ្វើដំណើរ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ វគ្គបណ្តុះបណ្តាល និងសេវាបកប្រែ ដោយត្រូវការថវិកាប្រមាណជា ៣៨១,០០០ដុល្លារ (តារាង១២) ប៉ាន់ស្មានដោយធនាគារពិភពលោក ដែលត្រូវបូករួមទាំងការចំណាយលើវិធានការកាត់បន្ថយផលប៉ះពាល់ជាក់លាក់ ដូចមានចែងក្នុផែនការដោះស្រាយផលប៉ះពាល់ ផែនការជនជាតិភាគតិច និងផែនការគ្រប់គ្រងសង្គម និងបរិស្ថាន។